## ២. សេចក្តីសំរេច

ភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៣

### សេចក្តីសំរេចលេខ ០១ សសរ ស្តីពីការផ្ទេរ

### នាយកដ្ឋានថាមពល នាយកដ្ឋានភូគព្ភសាស្ត្រ - រ៉ែ

### និង ក្រុមហ៊ុនអគ្គិសនីកម្ពុជាអោយស្ថិតនៅក្រោមការ

### គ្រប់គ្រងរបស់ក្រសួងថាមពល និង រ៉ែ

* * * *

**រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា**

បានឃើញក្រឹត្យចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះនៃកម្ពុជា

**សំរេច**

ប្រការ ១ ៖ ផ្ទេរ

- នាយកដ្ឋានថាមពល នាយកដ្ឋាភូគព្ភសាស្ត្រ - រ៉ែ ដែលចំណុះក្រសួងឧស្សាហកម្ម
- និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ដែលចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី នៃអតីតរដ្ឋកម្ពុជា ព្រមទាំងមន្ត្រីរាជការ និយោជិក ទាំងអស់ដែលនៅក្នុងអង្គភាពទាំង ៣ ខាងលើ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងថាមពល និង រ៉ែវិញ ។

ប្រការ ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិង រដ្ឋមន្ត្រីក្រសួងថាមពល និង រ៉ែ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្ថលេខា　　　　ហត្ថលេខា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ**　　　　**ហ៊ុន សែន**

www.pheakdeylaw.com